ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៩៣៧

ចុះថ្ងៃទី ១៩-១០-២០១១

សាលដីកា

លេខ ៖ ២៨ "ក្រ.III.ស"

ចុះថ្ងៃទី ២៣-០៥-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

៤៤៤ ★ ៣៣៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៩៣៧ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ស្រីដា ភេទស្រី អាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបី ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគីរី ទីលំនៅសព្វថ្ងៃភូមិ[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្ដីឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

ជាប់ចោទពីបទ: ប្រើប្រាស់ និងចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៦ ថ្មី និងមាត្រា ៩៨ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ១៣ និង៤០នាទី សមត្ថកិច្ចនគរបាលបានស្រាវជ្រាវ និងបង្ក្រាបទីតាំងចែកចាយគ្រឿងញៀនមួយកន្លែងរបស់ឈ្មោះ [redacted] ហៅ: ភេទប្រុស អាយុ ២

២៧ឆ្នាំ នៅភូមិវាល សង្កាត់គោកចក ខេត្តសៀមរាប។ បន្ទាប់មកសមត្ថកិច្ចដាក់ស្រាវជ្រាវបន្ត និងឃាត់ខ្លួនអ្នកចែកចាយ និងទិញបន្តជាច្រើននាក់ទៀត ដែលសរុបមានចំនួនជនល្មើស ១០នាក់ ខាងលើ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៥ ខ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ឱ្យឈ្មោះ [redacted] សុភ័ក្ត្រ ឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ [redacted] យាង រួចខ្លួន ពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោមៈ

ក- ឈ្មោះ [redacted] សុភ័ក្ត្រ ឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ [redacted] យាង ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១ខែ (មួយខែ) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

ពីបទ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៩៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ- ឈ្មោះ [redacted] ធីរិន ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] វីរៈ ដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួន ៤ខែ ១៥ថ្ងៃ (បួនខែដប់ប្រាំថ្ងៃ) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

គ- ឈ្មោះ [redacted] គិមហ៊ាង ដាក់ពន្ធនាគារកំណត់ ៦ខែ (ប្រាំមួយខែ) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

ពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី កថាខណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ឃ- ឈ្មោះ [redacted] ហោះ ដាក់ពន្ធនាគារកំណត់ ១៨ខែ (ដប់ប្រាំបីខែ) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

ង- ឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស៊ាន ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន គឺថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១១។

ពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី កថាខណ្ឌទី ២ មាត្រា ៤៨ ថ្មី និងមាត្រា ៤៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣- បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] សុភ័ក្ត្រ ឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ [redacted] យាង ចាប់ពី

ពេលនេះតទៅ។

៤- បន្តការឃុំខ្លួនលើឈ្មោះ [redacted] ធីរិទ្ធ ឈ្មោះ [redacted]វុទ្ធី ឈ្មោះ [redacted] វីរៈ ឈ្មោះ [redacted] គិមហ៊ាង ឈ្មោះ [redacted] ហោះ ឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស៊ាន រហូតអនុវត្តទណ្ឌកម្មចប់ជាស្ថាពរ។

៥- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ របស់ឈ្មោះ[redacted] ស្រីដា ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៥ ខ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។
- បានឃើញ ពាក្យសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ស្រីដា ជាជនជាប់ចោទ សុំដកពាក្យបណ្តឹងឧទ្ធរណ៍ដែលបានប្តឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៥ ខ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តសៀមរាប។
- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។
- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ[redacted] ស្រីដា បានឆ្លើយនៅសាលាដំបូងខេត្តសៀមរាប។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ របស់ជនជាប់ចោទឈ្មោះ[redacted] ស្រីដា ធ្វើឡើងក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍អាចលើកយកមកជំនុំជម្រះបាន ដោយយោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែ ដោយហេតុថា ជនជាប់ចោទឈ្មោះ[redacted]ស្រីដា បានដាក់ពាក្យសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១២ ហេតុនេះ គប្បីសភាព្រហ្មទណ្ឌ រក្សាទុកខ្លឹមសារនៃសេចក្តីសម្រេចដើមរបស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ

ជនជាប់ចោទឈ្មោះ[redacted]ស្រីដា បានសុំដកបណ្តឹងឧទ្ធរណ៍ តាមលិខិតដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១២ ដោយយល់ព្រមទទួលយកនូវការសម្រេចផ្តន្ទាទោសរបស់សាលាដំបូង ដែលបាន

សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៨៥ ខ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តសៀមរាប ដោយគ្មានការកែប្រែ សាលាឧទ្ធរណ៍គួរចំណាយរឿងចេញពីបញ្ជី។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

សាលាឧទ្ធរណ៍សម្រេចចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ ៩៣៧ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍ ចាប់ពីពេលនេះតទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ 6 ឆ្នាំ ២០១៤

ក្រឡាបញ្ជី